ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារប្រចាំឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.)

## I. សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងមាត្រា៤៨ បានចែងជាអាទិ៍ថា "**រដ្ឋធានាការពារសិទ្ធិកុមារ ដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ...**"។ ផ្តើមចេញពីគោលការណ៍នេះរាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវវិធានការណ៍គ្រប់បែបយ៉ាងសំដៅទប់ស្កាត់ និងការពារកុមារពីអំពើគាបសង្កត់ អំពើកេងប្រវ័ញ្ច អំពើជួញដូរ អំពើពេស្យាចារ និងអំពើហិង្សាគ្រប់រូបភាព តាមរយៈការបង្កើតយន្តការ និងពង្រឹងការអនុវត្តច្បាប់និងប្រព័ន្ធយុត្តិធម៌។

ឆ្លើយតបទៅនឹងគោលការណ៍ និងវិធានការណ៍ខាងលើរាជរដ្ឋាភិបាល បានបង្កើតនូវក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស និង**ឯកឧត្តម វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន និងមានតំណាងមកពីក្រសួង ស្ថាប័ន ជាអនុប្រធាន និងសមាជិក។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាយន្តការសម្របសម្រួល ពិនិត្យតាមដាន និងសរសេររបាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅលើកកម្ពស់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់អន្តរជាតិពាក់ព័ន្ធនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារព្រមទាំងប្តេជ្ញាចិត្តគោរព ការពារ និងបំពេញសិទ្ធិនានាចំពោះប្រជាពលរដ្ឋ ជាពិសេសកុមារ ក្នុងការរស់នៅប្រកបដោយសេរីភាពសេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាពស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ ដែលបានដាក់ចេញនូវវិធានការជាច្រើន រួមមាន ការអនុម័តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋាន យន្តការ កិច្ចសហការ ថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីធានាឲ្យបាននូវសុខុមាលភាព និងការគាំពារសង្គមចំពោះកុមារកម្ពុជា។

## II. ការងារសម្រេចបានរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ក្នុងរយៈពេលពេញមួយឆ្នាំ២០១៧ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានប្រឹងប្រែងបំពេញនូវតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ និងសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

## ១.ការងារការពារកុមារ និងពិនិត្យតាមដាន

- បានរៀបចំ និងបោះពុម្ពរបាយការណ៍ស្តីពីស្ថានភាពកុមារឆ្នាំ២០១៦ និងទិសដៅឆ្នាំ២០១៧ ដើម្បីបង្ហាញពីវឌ្ឍនភាពនៃការអនុវត្តសិទ្ធិកុមារ និងការឆ្លើយតបការអនុវត្តអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលបានលើកឡើងកាលពីពិធីមិទ្ទិញអបអរសាទរខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ១មិថុនា និងខួបលើកទី១៥ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៦។ របាយការណ៍នេះបានចែកជូនសមាជិករាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្រសួងស្ថាប័ន និងអង្គការមិនមែន រដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយក្នុងឱកាសប្រារព្ធពិធីមិទ្ទិញអបអរសាទរខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ១មិថុនា និងខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៧
- បាននិងកំពុងរៀបចំសេចក្តីព្រាងរបាយការណ៍ជាតិគួបលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា ជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។ ដើម្បីឱ្យសេចក្តីព្រាងរបាយការណ៍នេះ មានលក្ខណៈកាន់តែល្អប្រសើរ អគ្គលេខាធិការដ្ឋាន ក.ជ.ក. បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចំនួន ០៩លើក ដែល០១លើកៗ មានអ្នកចូលរួមចំនួនប្រមាណ ២០នាក់ (ស្រី០៦នាក់) គណៈកម្មការផែនការ និងរបាយការណ៍ចំនួន០២លើក ដែល០១លើកៗ មានអ្នកចូលរួមចំនួនប្រមាណ ៤០នាក់ (ស្រី១៣នាក់) និងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិជាមួយកុមារ ០១លើក មានអ្នកចូលរួមចំនួនប្រមាណ ៨០នាក់ (ស្រី ៤៣នាក់)
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ចំនួន០២លើក ស្តីពីការតាមដានការអនុវត្តសេចក្តីអង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ លើពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ និងស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ដែលមានអ្នកចូលរួមសរុប៥៨នាក់ (ស្រី១៦នាក់)។ លើកទី១ ពិគ្រោះយោបល់ជាមួយតំណាងកុមារ និងសង្គមស៊ីវិល និងលើកទី២ ពិគ្រោះយោបល់ជាមួយមន្ត្រីជំនាញ ដែលអញ្ជើញមកពីក្រសួងស្ថាប័នពាក់ព័ន្ធ ហើយលទ្ធផលដែលទទួលបានពីសិក្ខាសាលាពិគ្រោះយោបល់ទាំងពីរលើកនេះ ត្រូវបានបញ្ចូលទៅក្នុងសេចក្តីព្រាងរបាយការណ៍ជាតិគួបលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា
- បានសម្របសម្រួលជាមួយក្រុមការងារយុត្តិធម៌អនីតិជន នៃក្រសួង ស.អ.យ. ដោយមានកិច្ចសហការពីអង្គការយូនីសេហ្វ រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរយៈពេល០៣ឆ្នាំ សម្រាប់អនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ផែនការនេះ បានពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធចំនួន០៣លើក ដើម្បីប្រមូលនូវធាតុចូលសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការប្រតិបត្តិសម្រាប់អនុវត្ត ច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ សេចក្តីព្រាងផែនការនេះ ត្រូវបានប្រគល់ជូនក្រុមការងារយុត្តិធម៌អនីតិជនក្រសួង ស.អ.យ ដើម្បីបន្តនីតិវិធីក្នុងការស្នើសុំការសម្រេចពីថ្នាក់ដឹកនាំ
- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសនៃគណៈកម្មការការពារកុមារថ្នាក់ជាតិចំនួន០៤ លើកដើម្បីពិភាក្សាពីការបង្កើតគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារនៅកម្ពុជា និងបានប្រជុំពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិនិងក្រោមជាតិ ដើម្បីប្រមូលធាតុចូលក្នុងការរៀបចំគោលនយោបាយនេះ

- បានចុះសំណេះសំណាល និងស្វែងយល់ពីស្ថានភាពម្ដាយកុមារតូច និងអនីតិជននៅមណ្ឌលអប់រំកែប្រែ២ តាមរយៈការឧបត្ថម្ភគាំទ្រថវិកាពីកាកបាទក្រហមកម្ពុជា និងសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ។ ពិធីនេះរៀបចំឡើងក្នុងគោលបំណង ដើម្បីស្វែងយល់ពីស្ថានភាព និងសំណេះសំណាលសួរសុខទុក្ខម្ដាយកុមារតូច និងអនីតិជនជាប់ឃុំក្នុងមណ្ឌលអប់រំកែប្រែ២ និងចែកសម្ភារៈដែលជាតម្រូវការមូលដ្ឋានដល់មាតា ស្ត្រីពពោះ កុមារតូចនិងអនីតិជន។ ពិធីសំណេះសំណាលនេះ ដឹកនាំដោយលោកជំទាវ **អ៊ឹម ស៊ីថៃ** រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាអនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់ដឹកនាំ និងមន្ត្រីសរុបចំនួន១៧រូប
- រៀបចំកិច្ចប្រជុំបច្ចេកទេសជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្ដល់យោបល់លើលទ្ធផលការសិក្សាស្រាវជ្រាវស្ដីពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកមកលើកុមារ ដែលមានអ្នកចូលរួមមកពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការពាក់ព័ន្ធសរុបចំនួន៣១នាក់ (ស្រី៨នាក់)។ ជាលទ្ធផលរបាយការណ៍នេះត្រូវបានបោះពុម្ព និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ។

## ២. ការងារអប់រំ ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ធនធានមនុស្ស

- បានរៀបចំពិធីមិទ្ទិញអបអរសាទរខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ១មិថុនា និងខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ និងទិវាកុមារកម្ពុជាឆ្នាំ២០១៧ ដែលប្រារព្ធធ្វើនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ ក្រោមអធិបតីភាពរបស់លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅសាលមហោស្រពនៃមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រក្រោមប្រធានបទ "**លើកកម្ពស់ការចូលរួមរបស់កុមារដើម្បីអភិវឌ្ឍសង្គម**" និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ក្រោមប្រធានបទ "**សូមការពារកុមារពីពលកម្មកុមារនៅក្នុងស្ថានភាពជម្លោះ និងគ្រោះមហន្តរាយ**"។ ពិធីនេះមានអ្នកចូលរួមប្រមាណ ៣៤០០នាក់ ជាថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ភ្ញៀវជាតិ អន្តរជាតិ សិស្ស និស្សិត យុវជន ស.ស.យ.ក រាជធានីភ្នំពេញ កុមារកាយរិទ្ធ យុវជនស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា និងកុមារកំព្រា ពិការ ក្រីក្រ អនាថាដែលរស់នៅក្នុងមជ្ឈមណ្ឌល និងតាមសហគមន៍។ នាឱកាសនោះដែរ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក៏បានសហការជាមួយវិទ្យាស្ថានសិល្បៈភ្នំពេញអន្តរជាតិ រៀបចំការប្រឡងគូរគំនូររបស់កុមារ ដោយមានការចូលរួមពីកុមារា កុមារី និងសិស្សានុសិស្ស សរុបចំនួន ២១៥នាក់ ហើយកុមារដែលបានទទួលជ័យលាភីមានចំនួន៥៤នាក់
- បានផ្សព្វផ្សាយច្បាប់ស្ដីពីយុត្តិធម៌អនីតិជនដល់មន្ត្រីពាក់ព័ន្ធចំនួន ០២ខេត្ត គឺនៅខេត្តស្វាយរៀង និងខេត្តក្រចេះ ដែលមានអ្នកចូលរួមសរុបចំនួន៩៣នាក់(ស្រី៣២នាក់)។ តាមរយៈការផ្សព្វផ្សាយនេះ អ្នកចូលរួមបានយល់ដឹងអំពីខ្លឹមសារលម្អិតតាមមាត្រានីមួយៗនៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន សម្រាប់យកទៅអនុវត្តក្នុងការងារប្រចាំថ្ងៃ និងក្នុងអង្គភាពរបស់ខ្លួន
- បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីអនុសញ្ញាសិទ្ធិកុមារនៅខេត្តព្រះវិហារ ដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ចំនួន៣៤នាក់ (ស្រី១៧នាក់)។ វគ្គនេះមានគោលបំណងពង្រឹងសមត្ថភាព និងចំណេះដឹងបន្ថែមពាក់ព័ន្ធនឹងអនុសញ្ញាសិទ្ធិកុមារពិធីសារ ដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់ជាតិ និងក្រោមជាតិ។ ជាលទ្ធផលសិក្ខាកាមទាំងអស់បានយល់ដឹងពីសិទ្ធិកុមារ ច្បាប់ជាតិ និងអន្តរ

ជាតិដែលពាក់ព័ន្ធ

- បានបញ្ជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ចូលរួមវគ្គបណ្តុះបណ្តាល ចំនួន០៣វគ្គ គឺវគ្គស្តីពីការសរសេរ ពត៌មានថ្នាក់មូលដ្ឋាន វគ្គផលិតវីដេអូថ្នាក់មូលដ្ឋាន និងវគ្គស្តីពីការអភិវឌ្ឍគុណភាពជីវិត។ ឆ្លងតាមវគ្គបណ្តុះបណ្តាលនេះ មន្ត្រីអគ្គលេខាធិការដ្ឋានទទួលបានការបំប៉នសមត្ថភាពជំនាញបន្ថែមទៀត ដើម្បីយកចំណេះដឹងទាំងនេះមកបំពេញការងារឲ្យកាន់តែមានប្រសិទ្ធភាព
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីអនុសញ្ញាសិទ្ធិកុមារ ដល់មន្ត្រីនៃមន្ទីរវិស័យពាក់ព័ន្ធ ដែលជាសមាជិកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្តកំពង់ឆ្នាំង និងបាត់ដំបង និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សរុបចំនួន១០០នាក់ (ស្រី៤២នាក់) ដែលប្រព្រឹត្តទៅនៅទីរួមខេត្តកំពង់ឆ្នាំង និងបាត់ដំបង ហើយជាលទ្ធផលសិក្ខាកាមបានយល់ដឹងអំពីអនុសញ្ញាស្តីពីសិទ្ធិកុមារពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ច្បាប់ជាតិដែលពាក់ព័ន្ធនឹងកុមារ និងយន្តការអនុវត្តសិទ្ធិកុមារនៅកម្ពុជា ជាពិសេសអាចយកចំណេះដឹងទាំងនេះទៅអនុវត្តនៅក្នុងការងាររបស់អង្គភាពរៀងៗខ្លួន
- បានបញ្ជូនមន្ត្រីចំនួន៣នាក់ (ស្រី១នាក់) ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីសម្រាប់អង្គភាពថវិកា ចំនួន២លើក ដែលរៀបចំនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅទីស្តីការក្រសួង ស.អ.យ។ ជាលទ្ធផល អ្នកចូលរួមបានយល់ដឹង និងមានសមត្ថភាពក្នុងការអនុវត្តថវិកាតាមកម្មវិធី ដែលរាជរដ្ឋាភិបាលបានដាក់ចេញឲ្យក្រសួង ស.អ.យ. អនុវត្ត។

## ៣. ការងាររដ្ឋបាលផែនការនិងហិរញ្ញវត្ថុ

- បានសម្របសម្រួលរៀបចំកិច្ចប្រជុំផ្សព្វផ្សាយផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ២០១៦-២០១៨ និងជំរុញការបង្កើតក្រុមការងារដើម្បីកុមារនៅក្រសួង ចំនួន០៦ រួមមាន៖ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងបរិស្ថាន ក្រសួងធម្មការនិងសាសនា ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ។ ជាលទ្ធផលសាមីក្រសួងនីមួយៗបានសន្យាថា នឹងសុំគោលការណ៍ពីថ្នាក់ដឹកនាំក្រសួង ដើម្បីបង្កើតក្រុមការងារដើម្បីកុមារ និងបញ្ចូលសកម្មភាពដែលមាននៅក្នុងផែនការជាតិស្តីពីការអភិវឌ្ឍកុមារទៅក្នុងផែនការសកម្មភាពរបស់ក្រសួងរៀងៗខ្លួន
- បានរៀបចំចងក្រងរបាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររយៈពេល០៥ឆ្នាំ ២០១២-២០១៦ ជូនក្រសួង ស.អ.យ ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល និងរបាយការណ៍ស្តីពីការរៀបចំពិធីមិទ្ទិញអបអរសាទរខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ១មិថុនា និងខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៧ ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានកិត្តិយស នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- រៀបចំកិច្ចប្រជុំស្តីពីផែនការប្រតិបត្តិរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឆ្នាំ២០១៧ ក្នុងគោលបំណងបង្ហាញពីលទ្ធផលការងារ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឆ្នាំ២០១៦ បញ្ហាប្រឈម ទិសដៅឆ្នាំ២០១៧ និងកៀរគរធនធានសម្រាប់អនុវត្តផែនការប្រតិបត្តិរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. ឆ្នាំ២០១៧ ដែលមានអ្នកចូលរួម៣៨នាក់ (ស្រី១៧នាក់)។ តាមរយៈកិច្ចប្រជុំនេះមានអង្គការដៃគូ

មួយចំនួនចាប់អារម្មណ៍ និងផ្តល់ការគាំទ្រជាថវិកា និងបច្ចេកទេសដើម្បីអនុវត្តផែនការ នេះឲ្យទទួលបានជោគជ័យ ស្របតាមផែនការយុទ្ធសាស្ត្រ៥ឆ្នាំ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បានរៀបចំផែនការថវិកាប្រចាំ ឆ្នាំ២០១៨ ដល់២០២០ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដើម្បីដាក់បញ្ចូលក្នុងផែនការថវិការបស់ក្រសួង ស.អ.យ.
- បានរៀចំកិច្ចប្រជុំពិនិត្យ និងកែសម្រួលផែនការសកម្មភាពឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ជាលទ្ធផលកិច្ចប្រជុំបានកែសម្រួលនូវសូចនាករ និងសកម្មភាពមួយចំនួនដែលមានក្នុងផែនការនេះ ដើម្បីដាក់ជូនក្រសួង ស.អ.យ.
- បានរៀបចំរបាយការណ៍សម្មភាព និងហិរញ្ញវត្ថុប្រចាំខែជូនអង្គការដៃគូ និងអនុវត្តការងាររដ្ឋបាលប្រចាំថ្ងៃ។

## III. ការងារសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ

- បានសម្របសម្រួលវគ្គផ្សព្វផ្សាយអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមពាក់ព័ន្ធចំនួន០៦លើក ដែលរៀបចំដោយក្រុមការងារដើម្បីកុមារនៃក្រសួងឧស្សាហកម្ម និងសិប្បកម្មដល់មន្ត្រីនៃមន្ទីរឧស្សាហកម្មនិងសិប្បកម្ម ម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្មនៅក្នុងខេត្តកំពង់ស្ពឺ កំពត តាកែវ ស្វាយរៀង ក្រចេះរតនគីរី មណ្ឌលគីរី សៀមរាប កំពង់ឆ្នាំង បាត់ដំបង កំពង់ធំ ពោធិ៍សាត់ កែប ព្រៃវែង បន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ៃលិន ស្ទឹងត្រែង ព្រះសីហនុ កំពង់ចាម ត្បូងឃ្មុំ កោះកុង និងរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមសរុបចំនួន ១៦៩នាក់។ តាមរយៈវគ្គបណ្តុះបណ្តាលនេះអ្នកចូលរួមបានយល់ដឹងពីសិទ្ធិកុមារ ច្បាប់ពាក់ព័ន្ធនឹងកុមារ និងយកចំណេះដឹងផ្សព្វផ្សាយបន្តទៅដល់មន្ត្រីក្នុងស្ថាប័នអង្គភាព ម្ចាស់រោងចក្រ សហគ្រាសនិងសិប្បកម្ម ដែលមានទីតាំងនៅក្នុងរាជធានីខេត្តនីមួយៗ
- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជា រៀបចំវេទិកាតុមូលស្តីពីការអនុវត្តការងាររបស់គណៈកម្មការការពារកុមារថ្នាក់ជាតិ ក្នុងគោលបំណងបង្កើនការយល់ដឹងដល់សាធារណជនអំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ និងការពារសិទ្ធិកុមារតាមរយៈការបង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ និងជំរុញកិច្ចសហប្រតិបត្តិការរបស់សមាជិកគណៈកម្មការការពារកុមារថ្នាក់ជាតិ ដែលជាមន្ត្រីនៃស្ថាប័នកំពុងអនុវត្តកិច្ចការពារកុមារ ព្រមទាំងបង្ហាញអំពីយុទ្ធសាស្ត្រ និងវិធីសាស្ត្រដើម្បីបង្កើនកិច្ចការពារកុមារប្រកបដោយប្រសិទ្ធភាព។ វេទិកាតុមូលនេះមានវាគ្មិនចំនួន៤រូប ដែលអញ្ជើញមកពីក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកងរាជអាវុធហត្ថលើផ្ទៃប្រទេសនៃក្រសួងការពារជាតិ។ លទ្ធផលដែលបានពីវេទិកានេះ បានចាក់ផ្សាយតាមទូរទស្សន៍ជាតិកម្ពុជាចំនួន២លើក ដើម្បីឲ្យសាធារណជនទូទៅបានទស្សនា និងបានជ្រាប អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ និងការពារសិទ្ធិកុមារនៅកម្ពុជា។

## IV. ការងារសហការជាមួយអង្គការដៃគូពាក់ព័ន្ធ

- ដោយមានកិច្ចសហការ និងការគាំទ្រពីអង្គការចាប់ដៃ បានរៀបចំវគ្គបំប៉នសមត្ថភាពគ្រូបង្គោលស្តីពីគោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារ ដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បី

កុមារ និងសមាជិកអង្គការសម្ព័ន្ធចាប់ដៃសរុប២៧នាក់(ស្រី១៤នាក់) ដែលរៀបចំនៅខេត្តសៀមរាប។ ជាលទ្ធផលសិក្ខាកាមទាំងអស់អាចយកចំណេះដឹងនេះទៅបណ្តុះបណ្តាលបន្តដល់អ្នកពាក់ព័ន្ធ និងអាចយកចំណេះដឹងនេះទៅអនុវត្តក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន

- សហការជាមួយអង្គការចាប់ដៃ បានសម្របសម្រួលក្នុងសិក្ខាសាលាស្តីពីគោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារ ដល់សមាជិកអង្គការសម្ព័ន្ធចាប់ដៃ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សរុបចំនួន ៣៥នាក់ ក្នុងគោលបំណងលើកកម្ពស់ការអនុវត្តសិទ្ធិចូលរួមរបស់កុមារ ចែករំលែកបទពិសោធន៍ និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តការចូលរួមរបស់កុមារ។

## V. **បញ្ហាប្រឈម**

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ពុំទាន់មានកញ្ចប់ថវិកាដោយឡែកស្របតាមជំពូកទី៥ មាត្រា១៣ នៃ ព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់រាជធានី ខេត្ត និងក្រុមការងារដើម្បីកុមារតាមក្រសួង ស្ថាប័ន ពុំទាន់ផែនការសកម្មភាពការងារនិងកញ្ចប់ថវិកាច្បាស់លាស់
- ក្រុមការងារដើម្បីកុមារតាមក្រសួងស្ថាប័ន ដែលបានបង្កើតឡើងដំណើរការការងាររបស់ខ្លួននៅមានកម្រិតដោយឡែក ក្រសួង ស្ថាប័នមួយចំនួនពុំទាន់បង្កើតក្រុមការងារដើម្បីកុមារនៅឡើយ
- រចនាសម្ព័ន្ធ និងអាណត្តិរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅមានកម្រិត ពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលពុំអាចឈានទៅធ្វើការសម្របសម្រួលការងារអន្តរក្រសួងឲ្យមានប្រសិទ្ធភាព។

## VI. **សន្និដ្ឋាន និង សំណូមពរ**

ជារួមការបំពេញមុខងារទៅតាមភារកិច្ច និងតួនាទីរបស់ខ្លួនក្នុងរយៈមួយឆ្នាំនេះទទួលបានលទ្ធផលជាវិជ្ជមាន និងសម្រេចបាននូវសមិទ្ធផលជាច្រើនដែលបម្រើឱ្យផលប្រយោជន៍របស់កុមារកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ស្របតាមស្មារតីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ជាមួយគ្នានេះដែរក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សូមសំណូមពរដូចខាងក្រោមៈ

- សុំការគាំទ្រពីក្រសួង ស្ថាប័ន បង្កើតក្រុមការងារដើម្បីកុមាររបស់ខ្លួនឱ្យបាន
- សូមឱ្យមានកញ្ចប់ថវិកាដោយឡែកសម្រាប់អគ្គលេខាធិការដ្ឋាន និងកញ្ចប់ថវិកាជាក់លាក់របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់ខេត្ត រាជធានី
- សុំឱ្យមានការសហការគាំទ្រ ក្នុងការអនុវត្តនូវគោនយោបាយ និងផែនការជាតិនានា ដែលសម្របសម្រួលដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ស្នើសុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្តល់នូវមតិយោបល់និងនីតិវិធីផ្សេងៗចង្អុលបង្ហាញមកអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អាចមានលទ្ធភាពមានកញ្ចប់ថវិកាដោយឡែក។

## VII. **ទិសដៅបន្ត**

- បន្តរៀបចំសេចក្តីព្រាងរបាយការណ៍ជាតិលើកទី៤ ទី៥និងទី៦ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ជូនគណៈ

កម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ
- រៀបចំរបាយការណ៍វាយតម្លៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍន៍កុមារ ឆ្នាំ២០១៦-២០១៨
- រៀបចំបង្កើតផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍន៍កុមារ ឆ្នាំ២០១៩-២០២៣
- រៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយចំណេះដឹងស្តីពីសិទ្ធិកុមារ ពិធីសារបន្ថែមពាក់ព័ន្ធ និងស្តីពីគោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារដល់មន្ត្រីរាជរដ្ឋាភិបាលនិងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ
- រៀបចំពិធីមិទ្ទិញអបអរសាទរទិវាកុមារអន្តរជាតិ១មិថុនា និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៨
- បន្តកិច្ចប្រជុំគណៈកម្មការការពារកុមារថ្នាក់ជាតិដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាកុមារនៅកម្ពុជា
- រៀបចំកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ចុះពិនិត្យស្ថានភាពកុមារ នៅថ្នាក់ក្រោមជាតិ
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារនៅកម្ពុជា
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធលើគំនិតផ្តួចផ្តើមបង្កើតច្បាប់ ស្តីពីកិច្ចការពារកុមារនៅកម្ពុជា
- ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារនៅកម្ពុជានៅថ្នាក់ជាតិ និងក្រោមជាតិ
- រៀបចំរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុប្រចាំខែជូនក្រសួង ស.អ.យ និងអង្គការដៃគូរ និងអនុវត្តការងាររដ្ឋបាលប្រចាំថ្ងៃ។

ថ្ងៃ ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ,ថ្ងៃទី ខែធ្នូ ឆ្នាំ២០១៧

**ជ.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**អគ្គលេខាធិការ**

**ចំលងជូន**
- សមាជិក សមាជិកា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ឯកឧត្តមនាយកខុទ្ទកាល័យ ក្រសួង ស.អ.យ
- ឯកសារ-កាលប្បវត្តិ